## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## លិខិតសូមគោរពជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយឥតឧបមា សូមសម្តែងអំណរសាទរយ៉ាងជ្រាលជ្រៅបំផុត ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសទទួលបាន"សញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកទំនាក់ទំនងនយោបាយ"នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ពីសាកលវិទ្យាល័យគ្រើក "Krirk" ។

ខ្ញុំបាទសូមសម្តែងការកោតសរសើរដ៏ខ្ពង់ខ្ពស់បំផុតចំពោះ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលមានគុណបំណាច់ដ៏ឧត្តុង្គឧត្តម និងជាអគ្គមគ្គុទេសក៍នយោបាយមួយរូប ដែលបានដឹកនាំប្រទេស ប្រកបដោយគតិបណ្ឌិត បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជា មានសុខសន្តិភាព ស្ថេរភាពសង្គម និងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ។

ការទទួលបានសញ្ញាបត្រនាពេលនេះ មិនត្រឹមតែផ្តល់នូវមហាកិត្តិយសចំពោះ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបានលើកកម្ពស់នូវកិត្យានុភាព និងមោទនភាពជាតិ សម្រាប់ប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស ដែលមានថ្នាក់ដឹកនាំប្រកបដោយគតិបណ្ឌិតឆ្លាតវៃ បានដឹកនាំប្រជាជាតិកម្ពុជា ឆ្ពោះទៅរកវឌ្ឍនភាព និងសម្បូរណ៍រុងរឿង ។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពជូនពរបវរមហាប្រសើរថ្លៃថ្លា ជូនចំពោះ **សម្តេចអគ្គ-មហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតអំពីខ្ញុំបាទ ។

ថ្ងៃអង្គារ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩

**សម្តេចពិជ័យសេនា ទៀ បាញ់**